# កិច្ចតែងការបង្រៀន

| | |
|---|---|
| កម្មវិធីសិក្សា | ឆ្នាំ: ២០១២ ឆមាសទី: ១ ថ្នាក់ទី: ២ |
| មុខវិជ្ជា | ភាសាខ្មែរ |
| ចំណងជើងមេរៀន | **ព្យញ្ជនៈផ្ញើជើង ផ្ង . ផ្ញ . ផ្ដ . ផ្ត . ផ្ន . ផ្យ . ផ្អ** |
| ឈ្មោះគ្រូ | **ហ៊ុន សំអេង** |
| កាលបរិច្ឆេទ | ០៥/១១/២០១២ |
| រយៈពេល | ២ ម៉ោង |

## I- វត្ថុបំណង:

ចំណេះដឹង : សិស្សប្រាប់ពី របៀបអាន និងសរសេរ ព្យញ្ជនៈផ្ញើជើង បានត្រឹមត្រូវ តាមរយៈការបង្ហាញរបស់គ្រូ ។

បំណិន : សិស្សមានសមត្ថភាព អាន - សរសេរ ព្យញ្ជនៈផ្ញើជើង បានត្រឹមត្រូវ តាមរយៈ ការអនុវត្តន៍ផ្ទាល់ ។

ឥរិយាបថ : បណ្ដុះស្មារតីសិស្ស ខិតខំអាន សរសេរ ព្យញ្ជនៈផ្ញើជើង និមួយៗឱ្យបាន ស្ទាត់ច្បាស់លាស់ ដើម្បីងាយស្រួល យកទៅអនុវត្ត ក្នុងជីវភាព រស់នៅប្រចាំថ្ងៃ ។

## II- សម្ភារឧបទេស:

- ចំពោះគ្រូ : សៀវភៅសិស្ស ទំព័រទី១២
- ចំពោះសិស្ស : សៀវភៅសិស្ស ទំព័រទី១២ ដីស ក្ដារឆ្នួន សៀវភៅសរសេរ ខ្មៅដៃ

## III- វិធីសាស្ត្របង្រៀន: គោលវិធីសិស្សមជ្ឈមណ្ឌល

## IV- ដំណើរការបង្រៀន:

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| • ពិនិត្យវត្តមាន និងអវត្តមាន<br>• ពិនិត្យអនាម័យសិស្ស<br>• ពង្រឹងវិន័យ | ជំហានទី១<br>• លំនឹងថ្នាក់ | • ប្រធានថ្នាក់រាយការណ៍ |

| | | |
|---|---|---|
| • ពិនិត្យសៀវភៅកិច្ចការរបស់សិស្ស<br><br>• អានពាក្យឱ្យសិស្សសរសេរ<br><br>• ម៉ោងនេះយើងសិក្សាមេរៀនថ្មី សរសេរចំណងជើងលើក្ដារខៀន រួចអានចំណងជើង | <u>ជំហានទី២</u><br>❖ កែកិច្ចការចាស់<br>• ធ្យូងថ្ម<br>❖ រំឭកមេរៀនចាស់<br>• ដើមត្នោត ធ្យូងថ្ម ធ្មិតធ្មង់<br>❖ ទំនាក់ទំនងមេរៀនថ្មី<br>• ផ្ង ផ្ង ផ្ត ផ្ត ផ្ន ផ្យ ផ្អ | • លើកសៀវភៅដាក់លើតុ<br><br>• ស្ដាប់ សរសេដាក់ក្ដារឆ្នួន អាន<br><br>• សង្កេត អាន |
| • សរសេរពាក្យ **ផ្វារ** នៅលើក្ដាខៀន រួចអានឱ្យសិស្សថាតាម<br>• នាំសិស្ស វិភាគពាក្យ តើពាក្យ **ផ្វារ** មានអក្សរអ្វីខ្លះ ?<br>• ឱ្យសិស្សសរសេរលើក្ដារឆ្នួន រួចអានទាំងអស់គ្នា ក្រុម បុគ្គល<br>• ចំពោះពាក្យផ្សេងទៀត បង្រៀនដូចពាក្យ **ផ្វារ** ដែរ ។<br><br>• ឱ្យសិស្សទាំងអស់គ្នាអានសារឡើងវិញ<br>• ឱ្យសិស្សយកសៀវភៅ កត់មេរៀននៅលើក្ដារខៀន | <u>ជំហានទី៣</u><br><u>មេរៀនៈ</u> <u>ព្យញ្ជនៈផ្ញើជើង</u><br>**ផ្ង ផ្ង ផ្ត ផ្ត ផ្ន ផ្យ ផ្អ**<br>• **ផ្វារ**<br><br>• **ផ្វារ**<br><br>• ពាក្យ **ផ្វារ**<br><br>• ផ្ងួត ផ្ងើ ផ្ងៀវ ផ្ដើម ផ្ដាំ ផ្ដិល ផ្នូក ផ្នូរ ផ្លិត ផ្លែ ផ្សាយ ផ្សារ ផ្សិត ផ្អាប់ ផ្អូម ផ្អែម ផ្ដាំផ្ញើ ផ្ដែផ្ដាំ ផ្នូកខ្សាច់ ផ្លែកផ្លោះ ផ្សះផ្សា ផ្អៀងផ្អង ។<br>• មេរៀនលើក្ដាខៀន<br>• មេរៀន | • សង្កេត អាន<br><br>• ពាក្យ **ផ្វារ** មានអក្សរ ផ ្វ ា រ<br>• សរសេរ ដាក់ក្ដារឆ្នួន អាន<br><br>• អនុវត្ត<br><br>• អានទាំងអស់គ្នា<br>• កត់មេរៀនដាក់សៀវភៅរៀងៗខ្លួន |
| • ឱ្យសិស្សរៀនយឺត ឡើងអានមេរៀន គ្រូជួយសិស្ស ពេលជួបការលំបាក | <u>ជំហានទី៤</u><br>❖ ពង្រឹងចំណេះដឹង<br>• មេរៀនលើក្ដាខៀន | • ឡើងអានមេរៀន លើក្ដាខៀន |
| • ពេលត្រលប់ទៅផ្ទះវិញ ឧស្សាហ៍រំលឹក មេរៀនផង។ ឱ្យសិស្សរសេរពាក្យ **ផ្សះផ្សារ** ឱ្យបាន១០ពាក្យ។ | <u>ជំហានទី៥</u><br>❖ កិច្ចការផ្ទះ និង បណ្ដាំផ្ញើ<br>• **ផ្សះផ្សារ** | • ស្ដាប់ និង អនុវត្តដាក់សៀវភៅកិច្ចការ |